ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

**សូមគោរពជូន**

**សម្តេចគគ្គមហាសេនាបតីតេជោ**

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា**

**ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧០ ឈានចូល ៧១ឆ្នាំ**

***សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !***

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ពោរពេញដោយក្តីសោមនស្សរីករាយ នៃពិធីចម្រើនជន្មាយុគម្រប់ ៧០ ឈានចូល ៧១ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ១៥កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសេចក្តីសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំកាកបាទក្រហមកម្ពុជា និងបំពេញសកម្មភាពមនុស្សធម៌ដ៏ឧត្តុង្គឧត្តម ឱ្យទទួលបានជោគជ័យថ្មីៗទៀត ជាពិសេសក្នុងការដឹកនាំចលនាមនុស្សធម៌នៃកាកបាទក្រហមកម្ពុជា។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងកោតសរសើរយ៉ាងក្រៃលែងចំពោះសមិទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់របស់ **សម្តេច** ដែលកន្លងមកតែងបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ដល់សុខទុក្ខរបស់ប្រជាពលរដ្ឋតាមរយៈសកម្មភាពមនុស្សធម៌ ការផ្តល់នូវកិច្ចគាំទ្រយុទ្ធនាការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារមកលើស្ត្រីនិងកុមារ ទប់ស្កាត់ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងទុរគតជន ស្ត្រីមេម៉ាយ កូនកំព្រា ពិសេសសកម្មភាពចុះជួយជនរងគ្រោះដោយសារទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗ ប្រកបដោយឆន្ទៈមោះមុតខ្លាំងក្លាដែលមិនអាចកាត់ថ្លៃបាន។ តាមរយៈសកម្មភាពដ៏ឧត្តុង្គឧត្តមនេះផងដែរ បានធ្វើឱ្យមានការគាំទ្រយ៉ាងផុសផុលពីគ្រប់មជ្ឈដ្ឋានជាតិ-អន្តរជាតិ និងបានរួមចំណែកយ៉ាងធំធេងដល់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចតេជោ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រលាញ់ ជួបតែសុភមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃច័ន្ទ ២ កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញទូរស័ព្ទលេខ ០២៣ ៨៨៣ ២៧៩ : generalsec@mod.gov.kh